N"06_Single11.qxd 06/16/2006 10:21 Morning Page 1

# ព្រាបសន្តិភាព

ផ្នែកអប់រំ

QPMW

ព្រឹត្តិបត្រព្រាបសន្តិភាព | អ្វីៗដើម្បីសន្តិភាព | ឆ្នាំទី២ លេខ០៦ ឧសភា ២០០៥

កំណាព្យ "គុណម្តាយ"

មិនថាទឹកមូត្រឬលាមក ម្តាយលាងបោកគក់ពេញៗដៃ ដែលកូនជ្រិញជ្រក់ជុះរាល់ថ្ងៃ មិនត្អូញត្អែរអ្វីថ្លៃនួនល្អង។

ទំព័រ៤



ស្ត្រីប្រឈមមុខនិងមេរោគអេដស៍

ប្រពន្ធគួរតែមានចិត្តក្លាហានក្នុងការនិយាយជាមួយប្តីរបស់ខ្លួនអំពីគ្រោះថ្នាក់នៃការឆ្លង

ទំព័រ៤



ទំនាស់ និង អំពើហិង្សា

"តើមនុស្សបរិសុទ្ធរាប់រយនាក់នឹងត្រូវស្លាប់ដោយសារតែទឹកនេះឬ?"

ទំព័រ២

# សូមឧទ្ទិសដល់វិញ្ញាណក្ខន្ធកុមារី ឡូត រិត សិស្សអប់រំក្រៅប្រព័ន្ធ



By Cheatta

តើ យុត្តិធម៌ មានដែរ ឬទេ ចំពោះ រាស្ត្រក្រីក្រ ដូចជា រូបខ្ញុំ !!!

កុមារី **ឡូត រិត** អាយុ១៤ឆ្នាំ ត្រូវបានជនដៃដល់រំលោភហើយសំលាប់កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ នៅភូមិ តាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល។ ដោយភាពក្រីក្រតោកយ៉ាកខ្លាំងពេកចំពោះក្រុមគ្រួសារ កុមារី រិត ពុំមានឱកាសបានទទួលការសិក្សានៅក្នុងសាលារដ្ឋដូចកុមារដទៃទៀតឡើយ។ បន្ទាប់ពីមានការរៀបចំអោយមានកម្មវិធីអប់រំក្រៅប្រព័ន្ធក្នុងភូមិដែលឧបត្ថម្ភឡើងដោយអង្គការ JS កុមារីរូបនេះបានមកទទួលការសិក្សាអស់រយៈពេលពីរឆ្នាំ ហើយបន្ទាប់មកក៏បានទៅរៀនបន្តថ្នាក់ទី៣ នៅសាលាបឋមសិក្សា ព្រៃគោល។ អង្គការ JS ក៏នៅតែបន្តការជួយឧបត្ថម្ភសម្ភារៈសិក្សា អង្ករនិងយានជំនិះដល់រូបនាងទៀតរហូតដល់ថ្ងៃនាងទទួលរងគ្រោះ។

ហេតុការណ៍នេះកើតឡើងប្រមាណម៉ោង១០ព្រឹក។ កុមារី រិត បានធ្វើដំណើរទៅក្រោយផ្ទះពីរនាក់ប្អូនស្រីម្នាក់ទៀត។ តែអកុសលអាក្រក់សំរាប់រូបនាង នាងបានអោយប្អូនស្រីត្រឡប់ទៅផ្ទះវិញដើម្បីដុតភ្លើងស្អុរឡោតដោយប្រាប់ថានឹងទៅតាមក្រោយ... តទៅទំព័រ៤

# អ្នកតែងកំណាព្យស្ត្រីដែលមានឧបនិស្ស័យពីធម្មជាតិ

អតីតសិស្សរៀនថ្នាក់ទី៩នៃសាលាបឋមសិក្សាបំពេញវិជ្ជាព្រៃពួច ឆ្នាំ ១៩៧៤ ជំនាន់ លន់ ណុល ។ អ្នកស្រីបានក្លាយខ្លួនជាអ្នកតែងកំណាព្យបច្ចុប្បន្នរស់នៅភូមិទន្លាប់ ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល។ ការសិក្សារៀនសូត្របានតិចតួចឯចំណេះដឹងខាងអក្សរសាស្ត្រក៏ស្តួចស្តើង ប៉ុន្តែដោយសារមានឧបនិស្ស័យពីកំណើតគួបផ្សំផងទើបធ្វើឱ្យអ្នកស្រីមានសមត្ថភាពពិសេសចេះតែងកំណាព្យដែលប្រកបដោយខ្លឹមសារពាក្យពេចន៍ចាប់ចុងជូនណែងណងពីរោះរណ្តំ។ បច្ចុប្បន្នកំណាព្យអ្នកស្រីកំពុងទទួលបានការនិយមគាំទ្រពីសំណាក់លោកអ្នកសិស្សានុសិស្សនិងប្រិយមិត្តអ្នកអានទូទៅ ជាពិសេសតាមរយៈការអានសៀវភៅកម្រងកំណាព្យភាគ១ដែលមានចំណងជើងថា **អនិច្ចាអ្នកស្រែ** ជាវណ្ណកម្មដំបូងបានចេញផ្សាយនាចុងឆ្នាំ២០០៤។ ក្នុងរយៈពេលកន្លងមកជារឿយៗអ្នកស្រីតែងឆ្លៀតពេលទំនេរពីការងារសមាគមនារីប្រចាំភូមិដើម្បីចំណាយពេលវេលា កម្លាំងកាយចិត្តនិងមនោសញ្ចេតនាសរសេរជាអត្ថបទកំណាព្យបានច្រើនជាបន្តបន្ទាប់។ សព្វថ្ងៃអ្នកស្រី **ណារី** មានអាយុ៤៥ឆ្នាំ មានស្វាមីជាគ្រូបង្រៀនបើកបររថយន្តនិងមានកូន ៥ នាក់ ។

ស្រុកកំណើតរបស់អ្នកស្រីនៅឯម្តុំផ្សារមីស្ស MICHE ក្រុងភ្នំពេញ។ អាយុបាន១០ឆ្នាំ តទៅទំព័រ២



By Sophal

អ្នកស្រី ខុង ណារី យកគ្រែធ្វើជាតុដើម្បីអង្គុយតែងកំណាព្យនៅក្រោមផ្ទះ និង ឆ្លៀតឃោលចៅស្រីក្នុងអង្រឹងផង

N”06_Single11.qxd 06/16/2006 10:21 Morning Page 2

# រឿង : ទំនាស់ និង អំពើហិង្សា

តើមនុស្ស បរិសុទ្ធ រាប់រយនាក់ នឹងត្រូវស្លាប់ ដោយសារ តែទឹក នេះឬ?



រឿង ” ហេតុអ្វីអ្នកប្រយុទ្ធគ្នា? ”

កាលពីព្រេងនាយមានសហគមន៍ពីររស់នៅសងខាងទន្លេមួយ ។ពួកគេបានរស់នៅដោយចុះសំរុងនឹងគ្នាក្នុងខណៈដែលគ្មានបញ្ហាអ្វីឡើយ ។ប៉ុន្តែក្រោយមកមានគ្រោះរាំងស្ងួតកើតឡើងហើយក្រុមទាំងពីរក៏មានចិត្តលោភលន់យ៉ាងខ្លាំង ។ ពួកគេគិតតែរៀងៗខ្លួនថាពួកគេគួរបានគ្រប់គ្រងទឹកទន្លេទាំងអស់ហើយសហគមន៍ម្ខាងទៀតមិនគួរបានទឹកនោះប្រើប្រាស់ជាដាច់ខាត ។ព្រោះតែហេតុនេះពួកគេចាប់ផ្តើមឈ្លោះប្រកែកគ្នា ។ជម្លោះនេះធ្វើអោយពួកគេខឹងគ្នាទៅវិញទៅមក ហើយបណ្តាលអោយពួកគេហៅឈ្មោះគ្នាអាក្រក់ទៅវិញទៅមកតាមកំហឹង ដើម្បីធ្វើអោយភាគីម្ខាងទៀតឈឺចាប់នឹងខឹងកាន់តែខ្លាំងឡើង។ ។ កាលណាមនុស្សម្នាក់ខឹងអ្នកនោះងាយនឹងធ្វើអោយអ្នកដទៃខឹងតាមដែរ ។ មិនយូរប៉ុន្មានពួកគេម្នាក់ៗខឹងគ្នាទៅវិញទៅមក សូម្បីតែអ្នកដែលមិនជាប់ទាក់ទងបញ្ហាពីដើមទីក៏ចូលរួមមានកំហឹងដែរ ។ នៅពេលនោះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការធ្វើសង្គ្រាមយ៉ាងលឿនបំផុត ។ នៅមុនសង្គ្រាមចាប់ផ្តើមបន្តិចព្រះពុទ្ធបានយាងមកដល់ដោយព្រះអង្គឈ្វេងយល់ថាមានបញ្ហាអ្វីមួយមិនស្រួល ។ ព្រះអង្គសួរទៅមនុស្សក្រេវក្រោធថា ”តើហេតុអ្វី?” ប៉ុន្តែគ្មាននរណាមួយដឹងពីមូលហេតុនៃជម្លោះនោះទេ ។ ពួកគេខឹងខ្លាំងពេករហូតភ្លេចពីមូលហេតុដំបូងដែលនាំអោយពួកគេចង់ធ្វើសង្គ្រាម ។ ឥឡូវនេះពួកគេចាប់ផ្តើមដឹងខ្លួនថាពួកគេទាំងអស់គ្នាជាមនុស្សឆោតល្ងង់ ។ ម្នាក់ៗសួរគ្នាថាតើសង្គ្រាមនេះធ្វើដើម្បីអ្វី? ប៉ុន្តែគ្មាននណាម្នាក់ដឹងទេហើយនៅទីបញ្ចប់ពួកគេត្រូវទៅសួរ **ស្តេចផែនដី** ដែលព្រះអង្គពន្យល់ថាពួកគេប្រយុទ្ធគ្នាដើម្បីទឹក ។ ព្រះពុទ្ធបានត្រាស់សួរថា ” តើនឹងមានមនុស្សប៉ុន្មាននាក់ស្លាប់បើអ្នករាល់គ្នាធ្វើសង្គ្រាម?” អ្នកទាំងអស់នោះបានឆ្លើយថា:”ជាការពិតណាស់ក្រាបទូលបើមានសង្គ្រាមកើតឡើងនោះនឹងមានមនុស្សរាប់រយនាក់ត្រូវស្លាប់ ”ព្រះពុទ្ធក្បង់ទឹកមួយបាតដៃពីទន្លេហើយសួរថា”តើមនុស្សបរិសុទ្ធរាប់រយនាក់នឹងត្រូវស្លាប់ដោយសារតែទឹកនេះឬ?” គ្រប់ៗគ្នានៅស្ងៀម ។

ខ្លឹមសាររឿង:

ជាការប្រសើរសំរាប់យើងក្នុងការព្យាយាមដោះស្រាយទំនាស់មុននឹងអោយក្លាយជាអំពើហិង្សាដែលបណ្តាលអោយមនុស្សជាច្រើនត្រូវរងទុក្ខវេទនា។ នៅពេលដែលយើងមានបញ្ហាកើតឡើងហើយមិនបានដោះស្រាយដោយទុកអោយបញ្ហានោះអូសបន្លាយពេលយូរទៅៗនោះធ្វើអោយមនុស្សមានអារម្មណ៍ខឹងសម្បារខ្លាំងឡើងៗដែលជាហេតុធ្វើអោយមនុស្សងាយស្រួលក្នុងការប្រយុទ្ធគ្នា។

ជួនកាលយើងមិនដឹងថា យើងប្រយុទ្ធគ្នាដើម្បីអ្វីផង។ យើងនឹងក្លាយជាអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ស្អប់ខ្ពើមខឹងសម្បារចំពោះអ្នកដទៃ។ នៅក្នុងសាច់រឿងនេះព្រះពុទ្ធបានបង្ហាញដល់មនុស្សរាល់គ្នាផងដែរថា ការប្រយុទ្ធអាចធ្វើអោយរងទុក្ខវេទនាជាងនេះ ហើយក៏គ្មាននរណាម្នាក់បានទទួលនូវអ្វីដែលពួកគេចង់បានទេ។

*ដកស្រង់ចេញពីសៀវភៅអង្គការកាត់បន្ថយអាវុធ WGWR*

# អ្នកតែងកំណាព្យ...

អ្នកស្រីនិងគ្រួសារឪពុកម្តាយបានមករស់នៅក្នុងភូមិព្រៃក្រាយ ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ហើយរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាព្រៃពួច ។ អ្នកស្រីរៀនបានពាក់កណ្តាលឆ្នាំនៃថ្នាក់ទី៩ប៉ុណ្ណោះនៅកំឡុងឆ្នាំ១៩៧៤។ បន្ទាប់មកនាពេលនោះពួកទាហានប៉ុលពតចូលកាន់កាប់អំណាចរូបអ្នកស្រីនិងម្តាយត្រូវបានជម្លៀសចេញពីភូមិអោយទៅកាន់តំបន់រំដោះដូចប្រជាជនឯទៀតៗដែរ ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ អ្នកស្រីនិងគ្រួសារបានមករស់នៅឯភូមិ ទន្លាប់ ឃុំព្រៃពួច ស្រុកភ្នំពេញ ខេត្តកណ្តាល។ អ្នកស្រីក៏បានចូលបំរើការងារក្នុងអង្គការ JS ជាបុគ្គលិកសមាគមនារីប្រចាំភូមិទន្លាប់រហូតសព្វថ្ងៃនេះបាន៥ឆ្នាំហើយ ។ អ្នកស្រីមានប្រសាសន៍ទៀតថា ដំបូងឡើយក្រៅពីការងារបណ្តាញនារីភូមិ អ្នកស្រីបានយកពេលខ្លះសរសេរកំណាព្យអោយក្មួយៗជាយុវជនពឹងពាក់អោយជួយតែងកំណាព្យតាមបែបយុវវ័យហើយទទួលរង្វាន់ជាប្រាក់កាសបន្តិចបន្តួច, នំ ឬស្ករគ្រាប់ ។ ល ។

អ្នកស្រីបានបង្ហើបទៀតថាដោយសារឃើញអ្នកស្រីមានប្រាជ្ញាឈ្លាសវៃប្លែកពីមនុស្សធម្មតា អាចតែងកំណាព្យបានយ៉ាងដូច្នេះទើបមានសំណូមពរយ៉ាងទទូចពីអ្នករួមការងារជាច្រើនសូមអោយអ្នកស្រីនិពន្ធកំណាព្យរៀបរាប់បែបពិពណ៌នាក្រោយពេលបុគ្គលិកអង្គការត្រឡប់មកពីធ្វើដំណើរកំសាន្តម្តងៗនិងនិពន្ធកំណាព្យតាមការផ្តល់ជាគំនិតស្របតាមប្រធានបទនិមួយៗ។ បច្ចុប្បន្ននេះអ្នកស្រីសរសេរកំណាព្យបានជាច្រើនអត្ថបទនិងជាច្រើន ទម្រង់ដូចជា :

បទកាកគតិ-បទកខ-បទពាក្យ៧-បទបថ្យាវដ្ត-បទបន្ទោលកាក-បទព្រហ្មគីតិ-បទជាប់ទង-បទពុំនោល-បទភុជង្គលីលា ។ ល ។

អ្នកស្រី **ខុង ណារី** ក៏បានឱ្យដឹងដែរថា ប្រការដែលអ្នកស្រីអាចតែងនិពន្ធជាពាក្យកាព្យបាននេះគឺដោយសារឧបនិស្ស័យពីធម្មជាតិផ្ទាល់តែម្តងពោលគឺក្រុមគ្រួសាររបស់អ្នកស្រីពុំមានឈាមជ័រជាអ្នកកវីនិពន្ធទេ ។ អ្នកស្រីបានថ្លែងប្រាប់ដោយអារម្មណ៍ស្រងូតស្រងាត់ថា អ្នកស្រីមិនបានបន្តការសិក្សាបន្ថែម *តទៅទំព័រ៣*

អោយបានវែងឆ្ងាយទេក្រោយពីរៀនបានតែត្រឹមថ្នាក់ទី៩ ចាស់នោះ។ អ្នកស្រីចាំបានថា មុននឹងឈប់រៀនកាល នោះឪពុកម្ដាយត្រូវបែកបាក់ព្រាត់ប្រាស់គ្នា អ្នកស្រីត្រូវ រស់នៅជាមួយម្ដាយនិងប្អូនតូចៗយ៉ាងវេទនាជាទីបំផុត ពេលប្រទេសកំពុងមានសង្គ្រាមប្រយុទ្ធបង្ហូរឈាមរវាង ទាហាន លន់ណុល ជាមួយទាហានខ្មែរក្រហម។ អ្នកស្រី បានបន្ដរំលឹកថែមទៀតថាកំណាព្យទី១ដែលអ្នកស្រីរៀន តែងដំបូងបង្អស់នោះអ្នកស្រីបានដាក់ចំណងជើងថា "**ជីវិតក្មេងកំព្រាឪពុក** "តែងពេលដែលអ្នកស្រីមានអាយុត្រឹម តែ ១២ ឆ្នាំ ប៉ុណ្ណោះ។

អ្នកស្រីបានរៀបរាប់ទៀតថាអ្នកស្រីធ្លាប់បាន និពន្ធនិងសូត្រកំណាព្យផ្ទាល់ថ្វាយព្រះករុណាព្រះបាទ **សម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី** ក្នុងឱកាស ព្រះអង្គយាងចូលរួមក្នុងពិធីទទួលរបាយការណ៍ស្ដីពី សកម្មភាពកំចាត់មីននាថ្ងៃទី១៧ខែវិច្ឆិកាឆ្នាំ២00៤ នៅ មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការបន្ទាយព្រាប នៃអង្គការ JS។ អ្នកស្រីមានអារម្មណ៍រំភើបយ៉ាងក្រៃ លែងហើយនេះគឺជាមោទនភាពនិងជាជោគជ័យសំរាប់ ជីវិតអ្នកស្រីដែលបានព្រះករុណាយកព្រះទ័យទុកដាក់ ចំពោះអត្ថន័យខ្លឹមសារកំណាព្យ **ទំនួញកុមាររងគ្រោះដោយសារមីន** ព្រមទាំងទទួលនូវព្រះរាជអំណោយជា រង្វាន់ផ្ទាល់ពីព្រះករុណាផង។ អ្នកស្រីមានប្រសាសន៍ ឱ្យដឹងទៀតថា ថ្មីៗនេះ កាលពីថ្ងៃ ទី៣0 មេសា ២00៥ វេលាម៉ោង ៩:៣0ព្រឹក លោកបូជាចារ្យ **អូមែរ - ហ្សីវ៉ាល់ដូ** ជាអគ្គនាយកព្រឹត្តិបត្រអ្នកនាំសារបានប្រគល់ ជូននូវរង្វាន់លើកទឹកចិត្តដល់អ្នកស្រីដែលបានផ្ញើអត្ថបទ កំណាព្យមកចូលរួមប្រលងប្រជែងដែលមានចំណងជើង ថា" **ឡោតមាស** "ការប្រគល់នេះបានធ្វើនៅការិយាល័យ ផ្សព្វផ្សាយពតិមានព្រះសហគមន៍កាតូលិក។ លោកឪពុក **អូមែរ** ក៏បានថ្លែងនូវការកោតសរសើរចំពោះកំណាព្យ ជាគតិអប់រំជាច្រើនរបស់អ្នកស្រីដែលមានជាអាទិ៍នៅក្នុង ទំព័រសៀវភៅកម្រងកំណាព្យភាគ១ **អនិច្ចាអ្នកស្រែ**។ នាពេលនោះដែរ អ្នកស្រីក៏បានជូនសៀវភៅកម្រង កំណាព្យភាគ២គុណម្ដាយដល់លោកបូជាចារ្យពិនិត្យផង ដែរ។ សូមបញ្ជាក់ដែរថាកំណាព្យគុណម្ដាយនេះកន្លងមក **ព្រឹត្តិបត្រ ព្រាបសន្តិភាព** កំពុងចុះផ្សាយជូនប្រិយមិត្ត អ្នកអានតាម លេខប្រចាំខែជាបន្តបន្ទាប់ ។ ឆ្លងតាមការចេញសៀវភៅកម្រងកំណាព្យភាគ២ក្នុង ពេលឆាប់ៗខាងមុខនេះ អ្នកស្រីពិតជានឹងបានទទួលនូវ ការគាំទ្រពីប្រិយមិត្តអ្នកអានថ្មីៗថែមទៀតក្នុងបំណង ចូលរួមលើកស្ទួយវប្បធម៌អក្សរសាស្ត្រ សិល្បៈ កំណាព្យ អោយស្ថិតស្ថេរគង់វង្សរីកចំរើនជាភិយ្យោភាព ។

ដោយ ឡុង សុផល

## តើស្ត្រីប្រឈមមុខបែបណាក្នុងការចំលងមេរោគអេដស៍ពីប្ដី?



ជាការពិតណាស់ប្ដីមួយចំនួន តែងតែឆ្លៀតឱកាសផឹកស៊ី ស្រវឹងស្រីញីក្មេងៗខាងក្រៅ ដោយមិនប្រើស្រោមអនាម័យ។ នេះជាមហាគ្រោះថ្នាក់បំផុតសំរាប់ប្រពន្ធ។ ប្រពន្ធគួរតែមានចិត្តក្លាហាន ក្នុងការនិយាយជាមួយប្ដីរបស់ខ្លួនអំពីគ្រោះថ្នាក់នៃការឆ្លងនិងការពារដោយប្រើស្រោមអនាម័យ។

នៅមានត

### កែពាក្យខុស លេខ០៥

| | |
|---|---|
| ផ្ដាច់ញា | ប្ដេជ្ញា |
| តតាំង | តាំង |
| រដ្ធាភិបាល | រដ្ឋាភិបាល |
| សិខាសា | សិក្ខាសាលា |
| ខ្ពង់ខ្ពស់ | ខ្ពង់ខ្ពស់ |
| ស្រេក | ស្រក់ |
| អធិដ្ធាន | អធិដ្ឋាន |
| ស្រេចបាច់ | ស្រាច់បាច់ |
| ឈ្ងោកមេល | ឈ្ងោកមើល |

# សួនកំណាព្យ

## គុណម្ដាយ

បទពាក្យ៧

ភាគទី៥

មិនថាទឹកមូត្រឬលាមក ដែលកូនជ្រិញជ្រក់ជុះរាល់ថ្ងៃ
ម្ដាយលាងបោកគក់ពេញៗដៃ មិនត្អូញត្អែរអ្វីថ្លៃនូនល្អង ។
អាយុកូនកើនចំរើនវ័យ ម្ដាយស្នេហ៍បុត្រថ្លៃពេកកន្លង
កូនចេះមួយមុខម៉ែអរម្ដង អួតប្រាប់អ្នកផងមិនចាំយូរ ។
ទោះបីម៉ែហត់នឿយយ៉ាងណា មានថ្ពាល់បុត្រាគ្រាន់បន្ធូរ
ក្រសោបអោយថើបគ្មានគិតគូរ អារម្មណ៍ម៉ែធូរនិងថ្ពាល់កូន ។
កូននាងនៅតូចមិនដឹងក្ដី ម៉ែយកចំណីបញ្ចុកស្ងួន
ងូតទឹកដុសលាងសំអាតខ្លួន លើកកូននឹមនួនដាក់លើភ្លៅ ។
កូនមានអាយុបានប្រាំខែ អ្នកផងនៅក្បែរគេស្នេហ៍ពៅ
ចំណែកលោកពុកដែលជាឪ ប្រាប់អោយម៉ែទៅយកកូនមក ។
ពុកកូនគាត់ខ្លាចក្រែងអ្នកផង ដៃធន់កន្លងកាន់ពន្លក
ដណ្ដើមគ្នាពរឆក់ទៅមក ហើយខ្លាចមានរោគឆ្លងដល់កូន ។
ម៉ែប្រាប់ពុកកូនកុំកំណាញ់ ពួកគាត់ស្រឡាញ់ដូចបងប្អូន
ទើបគាត់មកសុំពររូបកូន ថើបបន្លែងស្ងួនព្រោះស្រឡាញ់ ។
មើលទៅកូនយើងមានព្រលឹង សាច់សម៉ត់ឈឹងគួរអោយខ្ចាញ់
ឯសក់ក្រហមរួញអង្កាញ់ មើលយូរស្រឡាញ់ថើបមិនណាយ ។
ម៉ែមើលមុខកូនដោយអាណិត ឱ! ស្រស់វរមិត្រកូនឆោមឆាយ
ហេតុម្ដេចក៏កូនកើតនិងម្ដាយ អ្នកក្រស្រុកអាយឯណេះវិញ ។
សាច់ឈាមស្រស់ថ្លារបស់កូន សមតែមាសស្ងួនកើតភ្នំពេញ
អ្នកមានទ្រព្យធនឯណោះវិញ មានទ្រព្យបំពេញបំណងកូន ។
ជីវិតម៉ែក្រសែនតោកយ៉ាក រស់សែនលំបាកស្ទើរតែសូន្យ
រំពឹងពុកឯងប្រឹងស្ដមខ្លួន រកគ្រប់ចំនួនព្រោះគ្រួសារ ។
តែដល់កូនកើតជាទារក ម៉ែថើបជញ្ជក់សព្វកាយា
បីបមថ្នាក់ថ្នមផ្ទប់ឱ្យា ម្ដាយប្រឹងរក្សាដោយចិត្តស្មោះ ។
ម៉ែខ្លាចតែកូនមានជំងឺ ពេលកូនម៉ែឈឺមុខស្លាំងអស់
បំបៅដល់កូនឈាមទឹកដោះ មិនសំរាន្តសោះវាស់ៗ ព្រឹក ។
កូនមានអាយុប្រាំបីខែ ចិត្តរបស់ម៉ែចេះតែនឹក
កូនចេះអង្គុយកកិលសឹក ម៉ែភ័យតែងនឹកខ្លាចកូនធ្លាក់ ។
យប់ថ្ងៃ ថ្ងៃយប់កន្លងទៅ ប្ដូរផ្លាស់រដូវតាមជាន់ថ្នាក់
អាយុកូនកើនច្រើនវ័យជាក់ ចេះដើរតេះតះដាស់គេឯង ។
អង្គុយកកិលក្រោកឈរដើរ ទៅតាមដំណើរម៉ែស្វះស្វែង
ខំបង្ហាត់កូនមិនរអែង កូនកុំខ្លាចក្រែងឥតមានគ្រូ ។
សំដីភាសាមារយាទថ្លៃ ម៉ែជាទាសីដែលគិតគូរ
បង្ហាត់បង្រៀនមិនចាំយូរ ម៉ែគឺជាគ្រូរបស់កូន ។

*ដកស្រង់ពីសៀវភៅ កំរងកំណាព្យភាគ២ គុណម្ដាយ និពន្ធដោយ អ្នកស្រី ខុង ណារី*

ផ្នែកព័ត៌មាន និង និពន្ធ
នឿន តុងលាង ( Tin Tin )
សុខ អេង
សូ ណុត
*កែអត្ថបទ*
លោក នី ញ៉
លោក ឡុង សុផល
លោក កន្យា ប៉ុបអែណេ
លោក ជឹម សាវ៉ន
លោក សេង ជាត្ដា
លោក ឃួន សំអែល
កញ្ញា កុល សៀប

ព្រាបសន្តិភាព
ផ្ទះលេខ: ៩៦ ផ្លូវ ៥៩២
បឹងកកពីរ ទួលគក ភ្នំពេញ
ទូរស័ព្ទលេខ: 0២៣ ៨៨0 ១៣៩
0២៣ ៨៨0 ៤៥៥
ប្រអប់សំបុត្រ:
P.O.Box: 880 Phnom Penh
អ៊ីម៉ែល: jrscam@forum.org.kh
គេហ៍ទំព័រ: www.jrscambodia.org

N”06_Single11.qxd 06/16/2006 10:22 Morning Page 4

## ខ្ញុំមិនដែលធ្វើអោយនរណាម្នាក់ពិបាកចិត្តទេ ចុះហេតុអ្វីបានជាគេគ្មានចិត្តមេត្តាករុណា សូម្បីតែបន្តិចក៏គ្មានដែរ !!!

កុមារី **ឡូត វិត**

អាយុ ១៤ ឆ្នាំ

មានប្អូនស្រី ៤នាក់ ប្រុស ២នាក់

រៀននៅសាលាបឋមសិក្សាព្រៃគោល

ឪពុក **តូ ឡូត** មុខរបរៈ ឡើងត្នោត

ម្តាយ **សែម រ៉ែម** មុខរបរៈ កាប់អុសលក់

ទីកន្លែងកំណើតៈ ភូមិ តាពេជ ឃុំឈ្វាំង

ស្រុកពញាឮ ខេត្តកណ្តាល ។



អង្គការមេត្តាករុណាបាន ជួយអង្ករឧត្តម្ភដល់គ្រួសារ ឡូត វិត

By Cheatta



**ឡូត វិត** និង កូនសិស្សក្នុងភូមិ **តាពេជ** ទទួលសម្ភារៈសិក្សាពី អង្គការ JS មុននឹងបន្តការសិក្សា នៅសាលារដ្ឋ។

តមកពីទំព័រ៤

ព្រោះនាងឈឺពោះហើយចូលគុម្ពោតព្រៃដើម្បីបត់ជើង ក្នុងពេលនោះជនល្មើសក៏បានចាប់នាងអូសចូលក្នុងព្រៃ។ ដោយសារតែខ្លួននៅក្មេងហើយកំលាំងខ្សោយមិនអាចស្រែកឮនិងរើបំរះបានជនល្មើសបានរំលោភយ៉ាងព្រៃផ្សៃបំផុតបន្ទាប់មកក៏បានផ្តាច់ជីវិតនាងដោយប្រើខ្សែក្រឡោសគោព័ទ្ធជុំវិញកនិងរឹតមួលដោយប្រើកំណាត់មែកព្រីងរហូតដល់នាងដាច់ខ្យល់ស្លាប់ ។ ម្តាយនាងឈ្មោះ**រ៉ែម** បានឆ្លេឆ្លារកកូនក្នុងពេលដែលគាត់ត្រលប់ពីរកអុសវិញមិនឃើញកូនស្រីរបស់គាត់ គាត់ដើរសួរអ្នកជិតខាងនិងដើររកមើលកូនស្រីតែមិនឃើញឡើយរហូតដល់ម៉ោងប្រមាណ២រសៀលទើបក្មេងឃ្វាលគោដើរបាញ់សត្វបានប្រទះឃើញសាកសពកុមារី **វិត** ក្នុងព្រៃល្បាស់ប្រមាណជា២០០ម៉ែត្រពីផ្ទះ ដោយមានស្រមោចរោមទៅហើយ។ បន្ទាប់មកក្មេងនោះបានរត់ទៅប្រាប់មីង **រ៉ែម** ត្រូវជាម្តាយរបស់ក្មេងស្រីនេះ។ ក្រុមគ្រួសារព្រមទាំងញាតិមិត្តជិតខាងមកចោមរោមឆោឡោនិងពោរពេញទៅដោយកំហឹងដល់ជនដែលគ្មានចិត្តមេត្តាធម៌បន្តិចសោះនោះ។ ភ្លាមៗនោះផងដែរក្រុមគ្រួសារបានរាយការណ៍ទៅប៉ូលីស ភូមិ ឃុំ ស្រុក ខេត្ត រហូតដល់ម៉ោង ១១ យប់ទើបប៉ូលីសបានពិនិត្យសាកសពនិងពេទ្យធ្វើកោសល្យវិច័យជាលទ្ធផលឃើញថាក្មេងស្រីនេះត្រូវគេរំលោភមែនបន្ទាប់មកសំលាប់ដើម្បីបំបាត់ភស្តុតាង។ សពនេះត្រូវរក្សានៅកន្លែងកើតហេតុរហូតដល់ពេលព្រឹកទើបសាច់សារលោហិតយកមកតំកល់ទុកលើគ្រែក្រោមដំបូលប្រក់ស្លឹកដែលជាកន្លែងធ្វើស្ករត្នោតស្ថិតនៅខាងមុខផ្ទះដ៏តូចចង្អៀត។ ទង់សនៅមុខផ្ទះនិង សំលេងភ្លេងបុណ្យសព **មីង រ៉ែម** ជាម្តាយអង្គុយលើគ្រែរនាបឫស្សីក្នុងសំលៀកបំពាក់ចាស់ៗ និងក្រមាក្រលាខៀវសជំនំបង់កបាននិយាយទាំងបង្ហូរទឹកភ្នែកថាៈ ” ខ្ញុំអាណិតកូនរបស់ខ្ញុំខ្លាំងណាស់ម្សិលមិញថ្ងៃសំរាកពីរៀនវាបានជួយរែកទឹកត្នោតឪវានិងជួយជញ្ជូនអុសខ្ញុំតែឥឡូវ.”។អ្នកមីងនិយាយបណ្តើរជូតទឹកភ្នែកបណ្តើរ ” ថ្ងៃមួយវានិយាយប្រាប់ឪវាថាវាមិនឈប់រៀនទេដើម្បីបានអង្ករចិញ្ចឹមគ្រួសារ ”។ ឯពូរបស់ក្មេងស្រីមានប្រសាសន៍ថា ”ក្មួយរបស់ខ្ញុំមិនសូវចេះមាត់ចេះកអីទេវាខិតខំរៀនសូត្រណាស់មនុស្សល្អបែបនេះហេតុអ្វីត្រូវស្លាប់ ” សិស្សានុសិស្សទូទាំងសាលាព្រៃគោលបានមកចូលរួមមរណៈទុក្ខកុមារីដ៏កំសត់នេះហើយសាកសពត្រូវសាច់ញាតិបូជានៅរសៀលម៉ោង៣ ថ្ងៃ២៨ មេសា ២០០៥។ កងកំលាំងនគរបាលអាជ្ញាធរកំពុងតាមដានឧក្រិដ្ឋកម្មនេះដើម្បីស្វែងរកជនល្មើសដែលបានប្រព្រឹត្តអំពើសេពសន្ថវៈនិងសំលាប់នេះមកផ្តន្ទាទោសតាមច្បាប់។ រហូតមកដល់ពេលនេះឃាតករកំពុងត្រូវបានតាមរក។ By TinTin